ថ្ងៃទី២១ ខែមេសា ឆ្នាំ២០១០

# លិខិតអញ្ជើញមកយកព័ត៌មាន

ពិធីបិទវគ្គបណ្តុះបណ្តាលមួយនឹងប្រារព្ធឡើង ដើម្បីអបអរសាទរចំពោះសមិទ្ធផលនៃកិច្ចខំប្រឹងប្រែងរបស់មន្រ្តីអង្គភាពប្រឆាំងអំពើពុករលួយចូលរួមក្នុងវគ្គបណ្តុះបណ្តាលមួយឈុត ដែលប្រើពេលអស់ជាច្រើនសប្តាហ៍កន្លងមក។ វគ្គបណ្តុះបណ្តាលមួយឈុតនោះរួមមានវគ្គបណ្តុះបណ្តាលស្តីពី៖ **វិធីសាស្រ្តនៃការសិក្សាស្រាវជ្រាវ យន្តការដោះស្រាយពាក្យបណ្តឹងនិងការគ្រប់គ្រងសំណុំរឿង ការប្រកាសទ្រព្យសម្បត្តិ និងការស៊ើបអង្កេតហិរញ្ញវត្ថុ** ។ ការចូលរៀនវគ្គបណ្តុះបណ្តាលតាំងពីដើមដល់ចប់ គឺជាសក្ខីភាពមួយបញ្ជាក់ពីការប្តេជ្ញាចិត្តរបស់អង្គភាពប្រឆាំងអំពើពុករលួយ ហើយក៏ជាជំហានវិជ្ជមានមួយបង្ហាញថាច្បាប់ប្រឆាំងអំពើពុករលួយថ្មីនេះនឹងអនុវត្តន៍ដោយត្រឹមត្រូវ ក៏ជាការត្រៀមលក្ខណៈជាស្រេចរបស់អង្គភាពប្រឆាំងអំពើពុករលួយ ដើម្បីក្លាយជាស្ថាប័នមួយមានប្រសិទ្ធភាពក្នុងគោលបំណងប្រយុទ្ធប្រឆាំងអំពើពុករលួយនៅកម្ពុជា។

ពិធីបិទវគ្គបណ្តុះបណ្តាលនេះនឹងប្រព្រឹត្តិទៅក្រោមអធិបតីភាពរបស់ឯកឧត្តម **នីយ រឿន** អនុប្រធានអង្គភាពប្រឆាំងអំពើពុករលួយ តំណាងរបស់ឯកឧត្តម **ឱម យ៉ិនទៀង** ទេសរដ្ឋមន្រ្តី និងជាប្រធានអង្គភាពប្រឆាំងអំពើពុករលួយ នៃទីស្តីការគណៈរដ្ឋមន្រ្តី និង លោក **ហ្វ្លីន ហ្វ៉ូលើ** ប្រធានបេសកកម្ម ទីភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិ (USAID) ។

ពិធីបិទវគ្គបណ្តុះបណ្តាលនេះនឹងប្រព្រឹត្តិទៅនៅថ្ងៃព្រហស្បត៍ ទី២២ ខែមេសា នៅវេលាម៉ោង២ និង៣០នាទី ដល់ម៉ោង៤រសៀល នៅមជ្ឈមណ្ឌលវប្បធ៌ម ទេសចរណ៍ និងពាណិជ្ជកម្មភ្នំពេញ ខែហ្គ ជីអ៊ីងប៊ុក ៕

****************************************

សម្រាប់ព័ត៌មានបន្ថែមទាក់ទងនឹងព្រឹត្តិការណ៍នេះ សូមទំនាក់ទំនងលោកស្រី ហួត រតនៈ អង្គការផេកកម្ពុជា តាមរយៈទូរស័ព្ទ ០១២ ៨០២៥៥១ ឬអ៊ីម៉ែល rhouth@pactworld.org